# ពីនេះពីនោះ

## អំណាចប្រជាពលរដ្ឋជំនះភាពក្រីក្រ



លេខរៀងទី

០១ តុលា ២០១៨

OXFAM

# មាតិកា


វិចារណកថា ៤

មាតិការឿង ៦

រឿងរបស់យើង ១០

ទស្សនវិស័យ ១៦

ព្រឹត្តិការណ៍ខាងមុខ ២០

ព័ត៌មាន ២១

អុកស្វាមនៅជុំវិញពិភពលោក ២៣

អំពីអុកស្វាម ២៤

សូមអរគុណដៃគូទាំងអស់គ្នា! ២៥

# វិចារណកថា

**មិត្តជាទីរាប់អាន**!

នាងខ្ញុំមានក្តីសោមនស្សរីករាយណាស់ ដោយបានចែករំលែកមិត្តអ្នកអានទាំងអស់គ្នា អំពីការចេញផ្សាយលើកដំបូង របស់ព្រឹត្តិបត្រប្រចាំត្រីមាសរបស់អង្គការអុកស្វាមដែលមានឈ្មោះថា «**ពីនេះពីនោះ**»។ ចំណងជើងនេះត្រូវបាន សហសេរិក និងមិត្តច្រើនលើសលុបជ្រើសរើស  នៅក្នុងដំណើរការរៀបចំព្រឹត្តិបត្រនេះ។ **ពីនេះពីនោះ** សំដៅលើ ការសន្ទនាសាមញ្ញលើប្រធានបទផ្សេងៗ រាប់ទាំងរឿងទូទៅ ដល់កិច្ចការនយោបាយ ដែលមានសារៈសំខាន់ដល់ ជនគ្រប់រូប។

យើងខ្ញុំចង់ឱ្យព្រឹត្តិបត្រ **ពីនេះពីនោះ** រួមចំណែកដល់ការចែករំលែកចំណេះដឹង និងការរៀនសូត្រ ទាក់ទងនឹងការអភិវឌ្ឍ សេដ្ឋកិច្ចសង្គម និងប្រជាធិបតេយ្យ នៅប្រទេសកម្ពុជា។ ក្នុងន័យនេះ ព្រឹត្តិបត្ររបស់យើងនឹងសហការជាមួយស្ថាប័ន រាជរដ្ឋាភិបាលដៃគូ អ្នកគាំទ្រ និងអ្នកផ្តល់ជំនួយ ព្រមទាំងសហការីរបស់អុកស្វាម ដើម្បីនាំមកជូនមិត្តទាំងអស់នូវរឿងរ៉ាវ ដែលកើតមានចំពោះប្រជាជនដែលយើងធ្វើការជាមួយ ក៏ដូចជាការរៀបចំគោលនយោបាយនានា ដើម្បីជួយគាំទ្រដល់ ប្រជាជន ជាពិសេសក្រុមដែលងាយរងគ្រោះដែលយើងធ្វើការជាមួយ នៅក្នុងពេលដែលពួកគេប្រឹងប្រែងប្រកបកិច្ចការ ដោយចីរភាពដើម្បីឈានចេញពីភាពក្រីក្រ។

រូបខ្ញុំបានកើតនៅចំពេលដែលកម្ពុជាស្ថិតនៅជាប្រទេសមួយរងការហែកហួរ ដោយសង្គ្រាម និងហ៊ុំព័ទ្ធដោយភាពក្រីក្រ តោកយ៉ាក។ ក្នុងនាមជាស្រ្តីខ្មែរមួយរូប ខ្ញុំមានមោទនភាពចំពោះបេសកកម្មរបស់អង្គការអុកស្វាមនៅក្នុងការប្រឆាំងនឹង ភាពក្រីក្រ និងអយុត្តិធម៌ផ្នែកសង្គម និងសេដ្ឋកិច្ច ដែលត្រូវគ្នាជាមួយនឹងជំនឿរបស់ខ្ញុំតែម្តង។ ខ្ញុំធ្លាប់បាននិយាយប្រាប់ មិត្តជាច្រើនហើយថា ការវិលត្រលប់មកកម្ពុជាវិញមកធ្វើជានាយិការបស់អុកស្វាមប្រចាំប្រទេស គឺពិតជាការងារក្នុង សុបិនមួយរបស់ខ្ញុំ។



អុកស្វាមបាននឹងកំពុងគាំទ្រដល់ប្រជាជនកម្ពុជានៅក្នុងការអភិវឌ្ឍរបស់ខ្លួនចាប់តាំងពីឆ្នាំ១៩៧៩ មក។ កាលនោះ វាគឺជាអន្តរាគមន៍មនុស្សធម៌សុទ្ធសាធ ដែលក្នុងនោះ អុកស្វាមខិតខំព្យាយាមឆ្លើយតបទៅនឹងតម្រូវការនានាជាមូលដ្ឋានរបស់ប្រជាជនកម្ពុជា។ ចាប់តាំងពីពេលនោះមក ប្រទេសកម្ពុជាមានការប្រែក្លាយគួរឱ្យកត់សម្គាល់ ដោយសម្រេចបានកំណើនសេដ្ឋកិច្ចជាទៀងទាត់ក្នុងកម្រិតមធ្យម ៧% ក្នុងមួយឆ្នាំ។

នៅក្នុងការដើរតាមគន្លងអភិវឌ្ឍន៍របស់កម្ពុជា កិច្ចអន្តរាគមន៍របស់អុកស្វាមខ្លួនឯង ក៏មានការប្រែប្រួលទៅតាមនោះដែរ នៅក្នុងអំឡុងពេលបួនទសវត្សរ៍កន្លងទៅនេះ។ ប្រសិនបើអ្នកសួរខ្ញុំថា តើអ្វីដែលអុកស្វាមគួរតែធ្វើ នៅក្នុងប្រទេសមានចំណូលទាប កម្រិតមធ្យមដូចជាប្រទេសកម្ពុជា ដែលការពិភាក្សាដេញដោលលែងផ្តោតទៅលើរឿង «កង្វះធនធាន» ទៀត ហើយ ប៉ុន្តែផ្តោតទៅលើ «អភិបាលកិច្ចធនធាន» វិញនោះ ខ្ញុំគ្រាន់តែអាចឆ្លើយបានថាវានៅតែចាំបាច់សម្រាប់ឱ្យអុកស្វាមបន្តធ្វើការជាមួយប្រជាជនកម្ពុជា តទៅមុខទៀត។ អុកស្វាមត្រូវតែជួយប្រជាជនកម្ពុជា ឱ្យបញ្ចេញឱ្យអស់នូវសក្តានុពលរបស់ខ្លួន ដើម្បីឈានទៅសម្រេចឱ្យបានកំណើនប្រកបដោយបរិយាប័ន្ន និងមានគណនេយ្យភាពសង្គមធំធេងថែមទៀត ជាពិសេសសម្រាប់ជាប្រយោជន៍ដល់ក្រុមជនងាយរងគ្រោះ។ យើងជឿថា «**គ្មានពលរដ្ឋកម្ពុជាណាម្នាក់គួរត្រូវបានមើលរំលងឡើយ**»។ ក្នុងស្មារតីនេះ អុកស្វាមប្តេជ្ញាចិត្តបន្តធ្វើការជាមួយតួអង្គពាក់ព័ន្ធទាំងអស់ ដើម្បីរកឱ្យឃើញនូវដំណោះស្រាយរយៈពេលវែងចំពោះបញ្ហាភាពក្រីក្រដ៏ស្មុគស្មាញ។

*មុននឹងបញ្ចប់ ខ្ញុំសូមអំពាវនាវសុំការរួមចំណែកពីមិត្តអ្នកអានទាំងអស់គ្នា! នៅក្រោមផ្នែកឈ្មោះថា ទស្សនវិស័យ យើងខ្ញុំចង់ធ្វើការរំលេចឡើងនូវទស្សនៈរបស់តួអង្គនានានៅក្នុងសង្គមកម្ពុជា នៅលើប្រធានបទសំខាន់ៗ ឱ្យបានទូលំទូលាយ។ ដូច្នេះ សូមអញ្ជើញផ្ញើអត្ថបទមតិយោបល់របស់លោកអ្នកទៅកាន់អ៊ីមែល Pineeh.Pinooh@cambodia.oxfam.org ហើយយើងនឹងយកទៅចុះផ្សាយអត្ថបទណាដែលមានន័យនិងទាក់ទាញបំផុត។*

*ខ្ញុំសង្ឃឹមថា មិត្តទាំងអស់នឹងទទួលបាននូវភាពរីករាយ ជាមួយការចេញផ្សាយលើកដំបូងរបស់ ពីនេះពីនោះ!*

**សូមជូនពរបវរថ្លៃថ្លាដល់មិត្តគ្រប់ៗគ្នា!**
**លីម សូលីន**

# មាតិការឿង



# កសិកម្មប្រកបដោយការច្នៃប្រឌិត នាំមកនូវសន្តិសុខស្បៀង និងហិរញ្ញវត្ថុ

**ការប្រែប្រួលអាកាសធាតុបានបង្កើតឱ្យមានភាពរាំងស្ងួតមិនទៀងទាត់ និងភ្លៀង និងទឹកជំនន់ខុសរដូវ ដែលធ្វើឱ្យប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់កសិករ។**

អង្គការអុកស្វាម សហការជាមួយអង្គការក្នុងស្រុកមួយឈ្មោះ រចនា បានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្មធន់នឹងអាកាសធាតុ ដើម្បីជួយកសិករឱ្យត្រៀមខ្លួន ធ្វើយ៉ាងណាបង្កើតប្រភពស្បៀងច្រើនជាងមុខសម្រាប់ការចិញ្ចឹមជីវិតប្រកបដោយចីរភាពទៅថ្ងៃអនាគត។

កសិករស្ត្រី គឺជាគោលដៅដ៏ចម្បងរបស់គម្រោងនេះ។ ក្នុងឆ្នាំ២០១៥ អុកស្វាមបានធ្វើការជាមួយអង្គការ រចនា និងអង្គការស្រែខ្មែរ បង្កើតគម្រោងមួយដែលមានឈ្មោះថា ក្រុមសេវាកសិកម្មដឹកនាំដោយស្ត្រី (Women-led Agriculture Service Team (WLAS)) ដើម្បីពង្រឹងសិទ្ធិអំណាចស្ត្រីនៅក្នុងវិស័យកសិកម្ម។ គោលបំណងរបស់គម្រោងនេះ គឺធ្វើយ៉ាងណា ជានាឱ្យបាននូវសន្តិសុខស្បៀង និងបង្កើនចំណូលដល់គ្រួសារ តាមរយៈការប្រើប្រាស់គោលការណ៍បច្ចេកទេសដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ និងផ្សាភ្ជាប់សេវារបស់ពួកគេទៅនឹងទីផ្សារ។

## វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្មធន់នឹងអាកាសធាតុ

ជាសមាជិកម្នាក់រូបនៃក្រុមសេវាកសិកម្មដឹកនាំដោយស្ត្រីប្រចាំស្រុកទ្រាំង ខេត្តតាកែវ លោកស្រី ប៉ុក ចន្ទវាសនា បានចូលសិក្សាវគ្គបណ្តុះបណ្តាលផ្តោតទៅលើផលិតកម្មដំណាំស្រូវ និងការចិញ្ចឹមមាន់។ បច្ចុប្បន្ន គាត់អាចប្រមូលផលស្រូវពីរដងក្នុងមួយឆ្នាំ ហើយឆ្នាំខ្លះរហូតដល់ទៅបីដងផង។ ក្រៅពីស្រូវ គាត់ដាំឪឡឹក បន្លែលើដីស្រែបន្ទាប់ពីច្រូតស្រូវបន្ថែមទៀត។ មិនត្រឹមតែប៉ុណ្ណោះ គាត់ចេះចាក់ថ្នាំវ៉ាក់សាំងឱ្យមាន់របស់គាត់ ដើម្បីទប់ស្កាត់ការឆ្លងជំងឺ និងចេះអំពីរបៀបផ្សំចំណីដែលធ្វើឱ្យមាន់ឆាប់ធំធាត់លឿន និងរក្សាមាន់ដាក់ក្នុងទ្រុងឱ្យបានត្រឹមត្រូវផងដែរ។ ដោយអនុវត្តនូវបច្ចេកទេសថ្មីដែលគាត់បានរៀនចេះខាងលើនេះ លោកស្រី ចន្ទវាសនា អាចរកចំណូលបានជិត ១០០០ដុល្លារអាមេរិក ពីការប្រមូលផលស្រូវមួយដង និងការលក់មាន់របស់គាត់ ហើយថ្មីៗនេះគាត់មានលទ្ធភាពទិញដីបីហិកតាបន្ថែមទៀត។ ប្រៀបធៀបទៅនឹងការរស់នៅកាលពីរ បីឆ្នាំមុន គុណភាពនៃជីវភាពរបស់គ្រួសារគាត់ មានភាពប្រសើរជាងមុនគួរឱ្យកត់សម្គាល់។ ដោយឃើញថាគ្រួសាររបស់គាត់មានស្បៀងគ្រប់គ្រាន់ហើយ លោកស្រី ចន្ទវាសនា ឥឡូវនេះអាចផ្ចង់ការយកចិត្តទុកដាក់ទៅលើការទំនុកបម្រុងកូនរបស់គាត់ឱ្យឈានទៅទទួលបានការអប់រំកម្រិតខ្ពស់។

*លោកស្រី សយ សុខុម និងប្តីរបស់គាត់ ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលរបស់អង្គការរចនា តាំងពីឆ្នាំ២០១៦ មក។ លោកស្រីមានប្រសាសន៍ថា៖ «មុនទទួលការបណ្តុះបណ្តាលនេះ ខ្ញុំអត់ចេះទេថាតើគួរដាំបន្លែរបៀបណានៅក្នុងរដូវប្រាំង។ កាលនោះ ខ្ញុំអាចដាំបន្លែបានតែមួយដង ឬពីរដងទេ ក្នុងមួយឆ្នាំ ដោយសារអត់មានទឹកគ្រប់គ្រាន់។»*

## ប្រភពស្បៀង និងការចិញ្ចឹមជីវិតកាន់តែមានចីរភាព

ឆ្លងតាមការបណ្តុះបណ្តាល គូស្វាមីភរិយានេះ សព្វថ្ងៃចេះរបៀបជ្រើសរើសប្រភេទបន្លែយកមកដាំឱ្យត្រូវតាមលក្ខខណ្ឌធាតុអាកាស។ ពួកគាត់ដឹងថាអាចដាំត្រកួនបានពេញមួយឆ្នាំ ដោយសារបន្លែប្រភេទនេះ មិនត្រូវការទឹកច្រើនទេ។ សម្រាប់ផលដំណាំមួយមុខៗ ឥឡូវនេះលោកស្រីអាចលក់បានប្រាក់ជិត ៥០០ ០០០រៀល (ប្រហែល ១២៥ដុល្លារ)។ ក្រៅពីនោះ លោកស្រី និងប្តីចិញ្ចឹមមាន់ថែមទៀត ដើម្បីបំពេញឱ្យប្រភពស្បៀង ដោយអាចរកលុយបាន ពី ៥០ដុល្លារ ទៅ ១០០ដុល្លារ ថែមទៀត។

លោកស្រី ចេង ស្រីម៉ាច និងប្តីរបស់គាត់ សម សារី បានប្តូរពីការចិញ្ចឹមជ្រូកមកចិញ្ចឹមមាន់វិញ ក្រោយពីបានទទួលការបណ្តុះបណ្តាលពីអង្គការរចនា។ នាង ស្រីម៉ាច បានបង្រៀនគ្រួសាររបស់គាត់ឱ្យដាន់ជើងលើកំបោរសជាមុនសិន មុននឹងឈានជើងចូលទ្រុងមាន់ ដើម្បីបង្ការការឆ្លងជំងឺដល់មាន់ដែលនៅក្នុងទ្រុង។

ជាផ្នែកមួយនៃគម្រោងនេះដែរ ក្រុមសន្សំប្រាក់ដើម្បីផ្លាស់ប្តូរមួយត្រូវបានបង្កើតឡើងនៅក្នុងភូមិ ក្នុងគោលបំណងដើម្បីជួយធានាឱ្យមានសន្តិសុខស្បៀង និងហិរញ្ញវត្ថុ។ អ្នកភូមិអាចសន្សំប្រាក់សម្រាប់ប្រើប្រាស់ក្នុងករណីត្រូវការបន្ទាន់ ព្រមទាំងសម្រាប់វិនិយោគទៅលើការទិញពូជស្រូវមានគុណភាពល្អ ពូជមាន់ និងជីសរីរាង្គ ដើម្បីទប់ទល់ជាមួយនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។

ការធ្វើកសិកម្មខ្នាតតូចដែលដឹកនាំដោយស្ត្រី មានភាពប្រសើរជាងមុនគួរឱ្យកត់សម្គាល់ ដោយសារតែគម្រោង និងគោលការណ៍ប្រកបដោយការច្នៃប្រឌិត ព្រមទាំងបានជំរុញឱ្យកសិករកាន់តែមានសមត្ថភាពធន់ជាងមុននឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។





*« ពេលធ្វើស្រែមុនដំបូងពិបាកមែនទែន! គ្រួសារខ្ញុំថា ធ្វើតែឯងទៅ អញមិនធ្វើចូលទេ! ខ្ញុំថា បើឯងមិនធ្វើ ខ្ញុំនឹងធ្វើ ដកពិសោធន៍! ដល់ពេលបានលទ្ធផលស្រូវល្អ បានគ្រួសារខ្ញុំគាត់ទៅមើល ហើយគាត់ក៏ថាធ្វើតាមវគ្គបណ្តុះបណ្តាល រចនា នឹងល្អមែនទែន! ហើយខ្ញុំក៏បានទៅរៀនវគ្គបណ្តុះបណ្តាល របៀបការចិញ្ចឹម ថែទាំមាន់ ទើបឥឡូវបានលក់ និងមានប្រាក់ចំនេញ ហើយឥឡូវក៏បានជោគជ័យ។ »*

លោកស្រី ប៉ុក ចន្ទវាសនា

# រឿងរបស់យើង

## ប័ណ្ណដាក់ពិន្ទុសហគមន៍សម្រាប់គណនេយ្យភាពសង្គម



**ប័ណ្ណដាក់ពិន្ទុសហគមន៍ គឺជាឧបករណ៍មួយត្រូវបានយកមកប្រើនៅក្នុងក្របខណ្ឌគណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា។ វាជាការវាស់វែងគណនេយ្យភាពដែលមានពលរដ្ឋជាកត្តាកំណត់ សម្រាប់ការស្ទង់មើលការរៀបចំផែនការ ការតាមដាន និងការវាយតម្លៃលើការផ្តល់សេវា។**

អង្គការស្តារកម្ពុជា ( STAR Kampuchea ) ប្រើប្រាស់តារាងពិន្ទុសហគមន៍នៅតាមតំបន់គោលដៅរបស់ខ្លួន សម្រាប់ឱ្យពលរដ្ឋធ្វើការវាយតម្លៃលើការផ្តល់សេវា នៅតាមមណ្ឌលសុខភាពឃុំ និងសាលារៀន។ វាផ្តល់ឱកាសឱ្យប្រជាពលរដ្ឋផ្តល់មតិត្រលប់មកវិញ ដើម្បីយកទៅកែលម្អការផ្តល់សេវាឱ្យកាន់តែប្រសើរឡើង ស្របតាមសេចក្តីត្រូវការរបស់ពួកគេ។

អង្គការអុកស្វាម បានសហការជាមួយអង្គការស្តារកម្ពុជា តាំងពីឆ្នាំ២០១៦មក ក្នុងការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម ( ISAF ) នៅក្នុងខេត្តស្វាយរៀង។ អុកស្វាមមានជំនឿថា ក្របខណ្ឌគណនេយ្យភាពសង្គមនេះនឹងលើកកម្ពស់ប្រជាធិបតេយ្យនៅមូលដ្ឋាន និងបង្កើនការផ្តល់សេវាសំខាន់ៗដល់ជនក្រីក្រ ឱ្យកាន់តែប្រសើរឡើងថែមទៀត។ ដើម្បីសម្រេចឱ្យបានជោគជ័យ ក្របខណ្ឌនេះចាំបាច់តម្រូវឱ្យមានការប្តេជ្ញាចិត្តយូរអង្វែង និងកិច្ចសហការក្នុងចំណោមបណ្តាក្រសួងពាក់ព័ន្ធនៅថ្នាក់ជាតិ អ្នកផ្តល់សេវា តួអង្គពាក់ព័ន្ធដែលត្រូវការសេវា និងអង្គការសង្គមស៊ីវិល។

### ការកែលម្អការផ្តល់សេវា

លោកស្រី សឿង រដ្ឋនី រស់នៅឃុំច្រេស ស្រុកចន្ទ្រា ខេត្តស្វាយរៀង។ លោកស្រីរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ២០១៥ ហើយសព្វថ្ងៃមានកូនប្រុសម្នាក់។ និយាយទៅកាន់អ្នកសម្របសម្រួលគណនេយ្យភាពឃុំនៅឯមណ្ឌលសុខភាព លោកស្រីមានប្រសាសន៍ថា៖ «កាលពីមុន មានការលំបាកខ្លាំងមែនទែន ក្នុងការស្វែងរកសេវាពីមណ្ឌលសុខភាពនេះ។» នៅក្នុងអំឡុងពេលដែលគាត់មានផ្ទៃពោះ លោកស្រីរដ្ឋនី ប្រើប្រាស់សេវានៅមណ្ឌលសុខភាព ប៉ុន្តែវាមិនមែនជារឿងងាយស្រួលទេ។ ផ្លូវដែលត្រូវឆ្លងកាត់ក្នុងការធ្វើដំណើរទៅកាន់មណ្ឌលសុខភាពនោះមានសភាពលំបាករួចទៅហើយ លើសពីនោះទៅទៀត មណ្ឌលសុខភាពក៏មិនសូវមានថ្នាំដែរ។ បុគ្គលិកក៏មិនមានចំនួនគ្រប់គ្រាន់ សម្រាប់បម្រើការងារពេញមួយថ្ងៃៗ។ អនាម័យក៏ជាបញ្ហាធំមួយដែរសម្រាប់អ្នកភូមិ។ យ៉ាងណាក៏ដោយ អ្នកភូមិនៅតែប្រើប្រាស់មណ្ឌលសុខភាពនោះ ពីព្រោះពួកគេគ្មានថវិកាសម្រាប់ចំណាយក្នុងការស្វែងរកការព្យាបាលនៅគ្លីនិកឯកជនទេ។

នៅក្នុងអំឡុងពេលជំនួបមួយជាមួយប្រធាន និងបុគ្គលិករបស់មណ្ឌលសុខភាព និងតំណាងពលរដ្ឋមកពីឃុំផង បញ្ហាទាំងអស់នេះត្រូវបានលើកឡើង ហើយដាក់ចូលទៅក្នុងផែនការសកម្មភាពគណនេយ្យភាពរួម ( JAAP )។ លោកស្រី រដ្ឋនី មានប្រសាសន៍ថា៖ «ខ្លួនខ្ញុំផ្ទាល់យល់ឃើញថា មានការផ្លាស់ប្តូរនៅក្នុងមណ្ឌលសុខភាពរបស់យើង តាំងពីពេលយើងចាប់ផ្តើមអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គមមក។ ខ្ញុំសង្កេតឃើញថា ថ្នាំមានច្រើនជាងមុន គិលានុបដ្ឋាយិកាក៏មានមកធ្វើការច្រើនជាងមុនដែរ ហើយអ្វីដែលសំខាន់ជាងនេះទៅទៀត គឺអនាម័យត្រូវបានកែលម្អឱ្យកាន់តែប្រសើរឡើង។ ខ្ញុំគិតថានេះប្រហែលជាមកពីលទ្ធផលនៃការប្រើប្រាស់ក្របខណ្ឌអនុវត្តគណនេយ្យភាពសង្គមហើយ។»



# កសិករផលិតស្រូវសរីរាង្គ ប្រើបច្ចេកវិទ្យាដើម្បីលក់ស្រូវបានតម្លៃសមរម្យ

**ឆ្នាំនេះ អង្គការអុកស្វាម បានសម្ពោធគម្រោងសាកល្បងមួយក្នុងប្រទេសកម្ពុជា ដែលមានឈ្មោះថា «ប្លុកឆេន ដើម្បីលើកកម្ពស់ជីវភាពកសិករស្រូវសរីរាង្គពីប្រទេសកម្ពុជា» ហៅកាត់ «ប្លុករ៉ាយស៍» ( BlocRice ) ដោយប្រើបច្ចេកវិទ្យា «ប្លុកឆេន (blockchain)» សម្រាប់បង្កើតបណ្តាញកសិករមួយនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ស្រូវអង្ករ ដើម្បីធានាយ៉ាងណាឱ្យកសិករទទួលបានថ្លៃល្អ និងសមរម្យពីការលក់ទិន្នផលរបស់ខ្លួន។**

កសិករដាំស្រូវសរីរាង្គខ្នាតតូចចំនួន៥០នាក់ នៅខេត្តព្រះវិហារបានចូលរួមសហការនៅក្នុងគម្រោងសាកល្បងនេះហើយ។ គោលបំណងគឺ ដើម្បីលើកកម្ពស់«កិច្ចសន្យាឆ្លាត» ដែលជាកិច្ចព្រមព្រៀងឌីជីថលបីភាគី រវាងកសិករដាំស្រូវសរីរាង្គ អ្នកនាំចេញអង្ករ និងអ្នកទិញនៅប្រទេសហូឡង់។ លោកស្រី លីម សូលីន នាយិការបស់អង្គការអុកស្វាមប្រចាំនៅកម្ពុជា មានប្រសាសន៍ថា៖ «តាមរយៈកិច្ចសន្យានេះ កសិករមានលទ្ធភាពតថ្លៃជាសមូហភាព ដោយសារថាក្រុមសហគមន៍កសិកម្មនឹងក្លាយខ្លួនជាភាគីនៅក្នុងកិច្ចសន្យាដែរ។»

គម្រោងនេះ ចុះបញ្ជីសមាសភាពគ្រប់យ៉ាងទាំងអស់ ដែលមាននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ដោយប្រើកូដអត្តសញ្ញាណកម្មមានលក្ខណៈពិសេសដោយឡែកនៅលើប្លុកឆេន។ បន្ទាប់មក វាបង្កើតជាកិច្ចសន្យាឆ្លាតមួយរវាងភាគីទាំងអស់ដែលចូលរួម។ នៅពេលណាផលិតផលត្រូវបានដឹកដល់ដៃអ្នកទិញហើយ ការទទួលយកទំនិញនឹងត្រូវបានកត់ត្រាទុកជាលក្ខណៈឌីជីថល ហើយការបង់ប្រាក់នឹងត្រូវបានផ្ទេរតាមប្រព័ន្ធឌីជីថលដែរ ទៅឱ្យសហគមន៍កសិកម្ម ដែលបន្ទាប់មកនឹងផ្ទេរប្រាក់បន្តទៅទៀតទៅឱ្យគណនីផ្ទាល់ខ្លួនរបស់កសិករ នៅតាមធនាគារក្នុងស្រុកណាមួយ។

Web-based application នេះផ្តោតទៅលើតម្លាភាព និងភាពអាចតាមដានបាន ហើយវាបង្កលក្ខណៈឱ្យភាគីទាំងអស់ធ្វើការសម្របសម្រួល ផ្ទៀងផ្ទាត់ និងដាក់កិច្ចសន្យាឱ្យប្រតិបត្តិតាម និងបំពេញមុខងារដោយគ្រប់ភាគីទាំងអស់ តាមប្រព័ន្ធឌីជីថល។ តួអង្គពាក់ព័ន្ធទាំងអស់អាចចូលមើលព័ត៌មានអំពីខ្សែសង្វាក់ផ្គត់ផ្គង់នៅលើទិន្នន័យរួមបាន ចាប់តាំងពីពេលដាំដុះស្រូវ រហូតដល់ពេលផលិតចេញជាអង្ករ។

## នាំយកការអនុវត្តដ៏ប្រសើរមកកម្ពុជា

នៅក្នុងប្រព័ន្ធ BlocRice កសិករបានបញ្ចូលព័ត៌មានប្រវត្តិរូបសង្ខេប និងទិន្នន័យដាំដុះរបស់ខ្លួន មានដូចជាតំបន់ដាំដុះ និងទិន្នផលរំពឹងទុកជាដើម។ ផ្ទៃដីដាំដុះមានទំហំជាមធ្យមពីមួយទៅពីរហិកតា ដែលផលិតស្រូវសរីរាង្គបានពី ២,៥តោន ទៅ ៣តោន ក្នុងមួយឆ្នាំ។

លោកស្រី លីម សូលីន នាយិការបស់អង្គការអុកស្វាមប្រចាំនៅកម្ពុជា មានប្រសាសន៍ថា៖ *«លទ្ធភាពឱ្យកសិករចុះឈ្មោះធ្វើកិច្ចសន្យាតាមរយៈវេទិកាឌីជីថលនេះបាន សបញ្ជាក់ឱ្យឃើញអំពីសារៈសំខាន់របស់កសិករ។ BlocRice នឹងផ្តល់ឱ្យពួកគាត់នូវវេទិកាមួយដើម្បីពង្រឹងសិទ្ធិអំណាចរបស់ខ្លួន។»*

គម្រោង «ប្លុកឆេនដើម្បីជីវភាពកសិករស្រូវសរីរាង្គពីប្រទេសកម្ពុជា» កំពុងត្រូវបានអនុវត្តចាប់តាំងពីខែមេសា ឆ្នាំ២០១៨ រហូតដល់ខែមីនា ឆ្នាំ២០១៩។ ប្រសិនបើវាសម្រេចបានជោគជ័យ គម្រោងនេះមានគោលដៅថានឹងត្រូវបានពង្រីកទៅអនុវត្តនៅតាមខេត្ត និងលើដំណាំផ្សេងទៀតដែរ។

# បញ្ហាខ្ញុំ ដំណោះស្រាយខ្ញុំ

**តាមរយៈអង្គការដៃគូ អង្គការហ្វាពន្លឺសិល្បៈ អង្គការអុកស្វាម បានគាំទ្រក្រុមស្ត្រីចំនួន១២រូប មកពីសហគមន៍ក្រីក្រ ឱ្យពួកគាត់ចេះប្រើប្រាស់សិល្បៈ ដើម្បីអប់រំ ចែករំលែកដល់ប្រជាជនងាយរងគ្រោះក្នុងសហគមន៍ក្រីក្រ ក្នុងខេត្តបាត់ដំបង។**

«ខ្ញុំសម្រេចចិត្តចូលរួមក្នុងក្រុមល្ខោននេះ ដោយសារថារឿងនេះ ជារឿងជីវិតរបស់ខ្ញុំ ហើយវាឆ្លុះបញ្ចាំងពីបញ្ហាដែលខ្ញុំកំពុងតែជួបប្រទះ»។ តាមរយៈអង្គការហ្វារពន្លឺសិល្បៈ អុកស្វាមបានគាំទ្រដល់ស្ត្រី១២នាក់នៅក្នុងសហគមន៍ក្រីក្រ ដោយជួយពួកគាត់ឱ្យចេះប្រើសិល្បៈនៃការសម្តែងដើម្បីលើកកម្ពស់ការរួមបញ្ចូលជនងាយរងគ្រោះបំផុតដែលរស់នៅតាមតំបន់ក្រីក្រតោកយ៉ាកក្នុងខេត្តបាត់ដំបង។ គ្រឿងញៀន ល្បែងស៊ីសង អំពើហិង្សាក្នុងគ្រួសារ ... ការសម្តែងក្រោមចំណងជើងថា «បញ្ហារបស់ខ្ញុំ ដំណោះស្រាយខ្ញុំ» ដោយក្រុមល្ខោនខេត្តបាត់ដំបង ឆ្លុះបញ្ចាំងអំពីបញ្ហាទូទៅដែលសហគមន៍របស់ស្ត្រីទាំង១២រូបជួបប្រទះ។

*លោក ឈិត ចាន់ភារៈ ប្រធានគម្រោង និងជាសិល្បករល្ខោន នៃអង្គការហ្វារពន្លឺសិល្បៈ មានប្រសាសន៍ថា៖ «មុននឹងចូលរួមក្នុងគម្រោងនេះ ស្ត្រីទាំងនេះស្ថិតក្នុងចំណោមមនុស្សដែលត្រូវបានគេមើលរំលងជាងគេនៅក្នុងសហគមន៍របស់ខ្លួន។ ពួកគាត់អត់មានការងារធ្វើ ហើយត្រូវដើរសុំទានរាល់ថ្ងៃ ដើម្បីរស់។ យើងបានពិភាក្សាជាមួយគាត់ ហើយបណ្តុះបណ្តាលគាត់ឱ្យប្រើល្ខោនជាឧបករណ៍មួយ ដើម្បីកសាងភាពជឿជាក់ក្នុងខ្លួន និងបញ្ចេញមតិ។ឥឡូវនេះពួកគាត់លែងខ្លាចនឹងនិយាយឱ្យដឹងអំពីបញ្ហារបស់ខ្លួនទៀតហើយ។ តាមការនិយាយចេញមកក្រៅ និងតាមការស្វែងយល់អំពីបញ្ហារបស់ខ្លួន ពួកគាត់ដឹងខ្លួនថា មានលទ្ធភាពស្វែងរកដំណោះស្រាយសម្រាប់ឆ្លើយតបទៅនឹងបញ្ហាទាំងនោះ»។*

## និយាយចេញមក ឱ្យគេឮ

ម៉ុមមានអាយុ ២៩ឆ្នាំ ហើយកំពុងមានផ្ទៃពោះកូនទីបួនរបស់នាង។ នាងនិយាយថា៖ «ឆាកល្បែងស៊ីសងនេះគឺផ្អែកនៅលើរឿងក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំធ្លាប់ជាអ្នកលេងល្បែង ហើយប្តីខ្ញុំធ្លាប់ជាជនប្រមឹក។ យើងអត់មានមុខរបរទេ ហើយតែងតែបញ្ជូនកូនឱ្យទៅសុំទានតាមផ្លូវ។ ក្រោយមកខ្ញុំចូលរួមជាមួយក្រុមល្ខោនបាត់ដំបង សឹងថាដោយចៃដន្យទេ ហើយពេលនេះខ្ញុំពិតជារីករាយក្នុងការសម្តែងណាស់។ ខ្ញុំមានភាពជឿជាក់ក្នុងខ្លួនជាងមុន »។ ម៉ុម និងប្តី ពេលនេះមានការងារធ្វើខ្លះៗហើយ។ ហើយក៏ឈប់បញ្ជូនកូនឱ្យសុំទានតាមផ្លូវទៀតដែរ។ «ក្នុងនាមជាឪពុកម្តាយ យើងទាំងពីរនាក់មានអារម្មណ៍ថាមានការទទួលខុសត្រូវជាងមុនក្នុងការផ្គត់ផ្គង់គ្រួសារ។ វាជួយឱ្យយើងគិតអំពីបញ្ហារបស់យើង និងធ្វើឱ្យយើងចេះរៀនខ្មាសអំពីអាកប្បកិរិយារបស់យើង»។ តាមរយៈគម្រោងនេះ ស្ត្រីក៏ទទួលបានផងដែរ នូវជំនាញកសិកម្មសម្រាប់ប្រើរកចំណូលបន្ថែម។

បួនខែបានកន្លងទៅហើយ បន្ទាប់ពីមូលនិធិគាំទ្រដល់កម្មវិធីនេះត្រូវបានបញ្ចប់ ប៉ុន្តែស្ត្រីទាំង១២រូបនៅតែបន្តសម្តែងនៅឡើយ។

លោកស្រី ស្រី សុខា អ្នកឯកទេសភាពជាដៃគូ និងសម្របសម្រួល គម្រោង Voice របស់អុកស្វាម និយាយថា៖ «នេះគឺពិតជារឿងគួរឱ្យភ្ញាក់ផ្អើលមួយ ហើយជារឿងជោគជ័យមួយក្នុងចំណោមរឿងជោគជ័យជាច្រើនរបស់គម្រោង»។



# សូមនិយាយថា « ទេ » ចំពោះប្លាស្ទិក! អ៊ុកស្វាមនាំគ្នាសម្អាតផ្លូវ

**ទិវាសម្អាតពិភពលោក គឺជាគំនិតផ្តួចផ្តើមមហាជនដែលប្រព្រឹត្តឡើងជារៀងរាល់ឆ្នាំ នៅទូទាំងពិភពលោក អស់ពេលដប់ឆ្នាំមកហើយ។ ប៉ុន្តែ លើកនេះជាឆ្នាំទីមួយហើយ ដែលប្រទេសកម្ពុជាតាមរយៈក្រសួងបរិស្ថាន បានចូលរួមទិវានេះជាមួយប្រទេស១៥៥ផ្សេងទៀត។ បុគ្គលិករបស់អ៊ុកស្វាមសរុប ៣០នាក់ រួមដោយគ្រួសារ មិត្តភក្តិ កូនក្មេង និងទារកផង ក៏បានចូលរួមក្នុងទិវានេះដែរ ដើម្បីស្រាក់ដៃគ្នាជួយសម្អាតនៅជុំវិញផ្សាររាត្រី ក្បែរផ្សារចាស់ ក្នុងរាជធានីភ្នំពេញ។**

រយៈពេលប៉ុន្មានម៉ោងដែលយើងបានចំណាយដើម្បីនាំគ្នាប្រមូលសំរាម ជាពិសេសវត្ថុប្លាស្ទិក ញាត់ដាក់ក្នុងស្បោងធម្មជាតិនោះ វាមិនមែនគ្រាន់តែជាការសម្អាតផ្លូវទេ។ អ្វីដែលសំខាន់បំផុតនោះ គឺការលើកកម្ពស់ការយល់ដឹងរបស់អ្នកស្នាក់នៅតំបន់នោះ និងខ្លួនយើងផ្ទាល់អំពីបញ្ហាពាតត្បាតរបស់វត្ថុប្លាស្ទិក និងបញ្ហាការទុកដាក់សំរាម។



Liza Ordonez-Cooke អ្នកសម្របសម្រួលក្រុមបៃតងរបស់អ៊ុកស្វាមកម្ពុជា - ដែលជាក្រុមបុគ្គលិកស្ម័គ្រចិត្តមានគោលដៅស្វែងរកដំណោះស្រាយបែបធម្មជាតិ ដល់បុគ្គលិក និងការិយាល័យតាមប្រទេស - និយាយថា៖ *«បំណែកប្លាស្ទិកតូចៗទាំងនេះងាយនឹងគេមើលរំលងណាស់ ប៉ុន្តែនៅក្នុងរដូវភ្លៀងសំរាមទាំងនេះនឹងធ្លាក់ចូលទៅក្នុងប្រព័ន្ធទឹកធម្មជាតិ បង្កបញ្ហាដល់ផ្លូវទឹកហូរ នាំឱ្យមានទឹកជំនន់ ហើយថែមទាំងត្រូវបានត្រីស៊ីជាចំណីទៀតផង។»*

## លើកកម្ពស់ការយល់ដឹង

ដំបូងឡើយ ក្រុមរបស់យើងគិតថាតំបន់ផ្សាររាត្រីមានភាពស្អាតគួរសម ប៉ុន្តែលុះតែដល់ពេលយើងចាប់ផ្តើមមើលទៅលើផ្លូវ ដើម្បីរករើសសំរាម ទើបយើងបើកភ្នែកខ្លួនយើងធំៗ ហើយទទួលស្គាល់ថាយើងទាំងអស់គ្នា មើលសំរាមមិនឃើញជាយូរមកហើយ។ ខណៈដែលកម្មករប្រមូលសំរាមបានបំពេញកិច្ចការប្រមូលយកសំរាមធំៗចេញអស់ នៅក្នុងលក្ខខណ្ឌមួយដ៏លំបាក និងខ្វះអនាម័យក៏ពិតមែន ក៏នៅមានបំណែកតូចៗ របស់សំរាម នៅរាយប៉ាយលើផ្លូវដែរ ដោយសារតែការចោលសំរាមមិនបានត្រឹមត្រូវ។ គ្រាន់តែជិតមួយម៉ោងសោះ យើងប្រមូលកម្ទេចសំរាមញាត់បាន១៥ថង់ធំៗ ដែលមានសំរាមគ្រប់មុខ ក្នុងនោះដបប្លាស្ទិកត្រូវបានដាក់ដោយឡែក។ សំរាមភាគច្រើនមាន បំពង់បឺតជ័រ ស្បោងកៅស៊ូ គម្របដបជ័រ ក្រវិលកំប៉ុងភេសជ្ជៈ កន្ទុយបារី សំបកស្ករគ្រាប់ និងស្រោមចង្កឹះ ចម្រៀកប្លាស្ទិកហែកចេញពីកញ្ចប់អាហារ និងសំណល់កាតទូរសព្ទដែលគេបោះចោលក្រោយពីបានបញ្ចូលទឹកប្រាក់រួច។

## ភពផែនដីមួយកាន់តែមានសុខភាពល្អ និងកាន់តែមានចីរភាព គឺចាប់ផ្តើមពីយើងគ្រប់គ្នា!

ការថែរក្សាបរិស្ថានឱ្យស្អាត និងការដឹងខ្លួនអំពីរបៀបទុកដាក់សំរាមឱ្យបានត្រឹមត្រូវ គួរតែជាកិច្ចការប្រចាំថ្ងៃរបស់មនុស្សគ្រប់គ្នា សកម្មភាពរួមគ្នាដែលគេមើលឃើញពេលនេះ បានញ៉ាំងឱ្យមានប្រតិកម្មពីសំណាក់អ្នករស់នៅទីនោះ។ យើងទទួលបានសំបកដប និងការលើកមេដៃប្រាប់ជាសញ្ញាគាំទ្រ។ យើងបានឮគេនិយាយគ្នាអំពីទម្លាប់អាក្រក់ ក្នុងការគ្រវែងសំរាមចោលពាសវាល។ មនុស្សម្នាក់បាននាំគ្នាកាន់កែវជ័រភេសជ្ជៈទទេមកបោះចូលក្នុងស្បោងរបស់យើង ហើយគេនាំគ្នាសួរថា ហេតុអ្វីបានជាយើងធ្វើដូច្នេះ?



# យល់ដឹងអំពីសិទ្ធិ ដើម្បីធានាសុវត្ថិភាព

*«មានម្តងនោះ ភ្ញៀវម្នាក់បង្ខំឱ្យខ្ញុំផឹកស្រាបៀមួយដបឱ្យអស់។ បើទោះជាគាត់មិនគំរាមផ្ទាល់មកលើរូបខ្ញុំមែន ប៉ុន្តែខ្ញុំអាចមើលឃើញថាគាត់មានកាំភ្លើង។ ខ្ញុំគ្មានជម្រើសទេ ក្រៅតែពីបង្ខំខ្លួនខ្ញុំឱ្យផឹកអស់មួយដប។»*
នេះជាសម្តី នាង ស៊ីណាត ជាអ្នកធ្វើការនៅហាងលក់ស្រាបៀ។

ស៊ីណាត និយាយថា៖ «ភ្ញៀវខ្លះទៀតរអ៊ូថា រូបខ្ញុំមានវ័យចាស់បន្តិចហើយសម្រាប់ការងារនេះ ប៉ុន្តែខ្ញុំប្រាប់ទៅពួកគេវិញថា បើមិនឱ្យខ្ញុំធ្វើការហ្នឹង តើមានអ្វីផ្សេងដែលខ្ញុំអាចធ្វើបាន?» នាងអរគុណចំពោះក្រុមហ៊ុនស្រាបៀដែលនាងធ្វើការ ព្រោះនាងមិនបាច់ទៅធ្វើការនៅរោងចក្រកាត់ដេរ។ យ៉ាងណាក្តី ក្រៅពីប្រាក់កម្រៃតិចហើយបរិយាកាសការងារសម្បូរដោយការបំពាន សុរា និងគ្រឿងញៀននៅជុំវិញកន្លែងធ្វើការរបស់នាង គឺជាកង្វល់មួយដល់គ្រួសារនាងដែរ។ ស៊ីណាត និយាយទៀតថា៖ «ប្រាក់ខែរបស់ខ្ញុំគ្រាន់តែមួយគ្រប់សម្រាប់ថ្លៃជួលផ្ទះ និងអង្ករមួយបាវប៉ុណ្ណោះ។» គ្រួសារទាំងមូលពឹងផ្អែកលើចំណូលរបស់ប្តីដែលជាអ្នករត់ម៉ូតូឌុប និងប្រាក់ចំណេញបន្តិចបន្តួចដែលគ្រួសាររបស់នាងបានពីការលក់ស្រាសនៅភូមិកំណើតក្នុងខេត្តស្វាយរៀង។ ស៊ីណាតមកធ្វើការនៅភ្នំពេញនៅឆ្នាំ១៩៩៦។

ស៊ីណាត ជាសមាជិកមួយរូបរបស់សហព័ន្ធកម្មករផលិតអាហារ និងសេវាកម្ពុជា (CFSWF)។ នាងបានពន្យល់ថា សហព័ន្ធនេះបានជួយនាងឱ្យបានយល់អំពីសិទ្ធិរបស់នាង និងអំពីរបៀបការពារសិទ្ធិទាំងនោះ។ សមាជិករបស់សហព័ន្ធនេះជួបជុំគ្នាជាទៀងទាត់ដើម្បីពិភាក្សាបញ្ហាជាច្រើន។ សហព័ន្ធនេះ ក៏ឧបត្ថម្ភឱ្យមានថ្នាក់បង្រៀនភាសាខ្មែរប្រចាំសប្តាហ៍ ដល់កម្មករ និងកូនៗរបស់គេ ដើម្បីបង្កើនជំនាញភាសានិយាយ និងការសរសេរ ក៏ដូចជាបង្កើនភាពជឿជាក់ក្នុងខ្លួនដែរ។ ស៊ីណាត និយាយថា៖ «វាជារឿងប្រសើរណាស់ ប្រសិនបើមនុស្សគ្រប់គ្នាផ្តល់តម្លៃឱ្យខ្ពស់បន្តិចមកលើខ្ញុំ និងការងាររបស់ខ្ញុំ។» ស៊ីណាត សង្ឃឹមថា តាមរយៈការងាររបស់ CFSWF វប្បធម៌នៅជុំវិញនារីលក់ស្រាបៀ និងតម្លៃដែលពួកគាត់ទទួលបាននៅក្នុងសង្គម នឹងមានការកែលម្អឱ្យប្រសើរជាងមុន៕

# រស់នៅក្នុងភាពភ័យខ្លាច ជាតម្លៃមួយខ្ពស់ពេក សម្រាប់ប្រជាជនតាមដងទន្លេមេគង្គ

**ការបាក់ទំនប់របស់គម្រោងវារីអគ្គិសនី Xe Pian-Xe Namnoy បាននាំមកនូវសោកនាដកម្ម ដែលក្នុងនោះ មនុស្សជាច្រើននាក់ស្លាប់ ហើយរាប់ពាន់នាក់ផ្សេងទៀត គ្មានផ្ទះសម្បែងរស់នៅ ជាមួយនឹងរបរចិញ្ចឹមជីវិត ក៏ត្រូវបំផ្លិចបំផ្លាញអស់ដែរ។**

ការប្រកាសរបស់រដ្ឋាភិបាលឡាវស្តីពី វិធានការបន្ទាន់ដែលត្រូវធ្វើ គឺជារឿងមួយគួរទទួលបានការកោតសរសើរ ប៉ុន្តែ សេចក្ដីសម្រេចចិត្តនេះបានបាត់ពន្លឺនៃសេចក្ដីសង្ឃឹមទៅវិញ ខណៈដែលវិធានការវាយតម្លៃ នៅតែបន្តទៅលើសំណើគម្រោងទំនប់វារីអគ្គិសនីប៉ាក់ឡាយត្រូវបានស្នើឡើង ហើយវាធ្វើឱ្យយើងទាំងអស់គ្នានៅតែមានក្ដីព្រួយបារម្ភ ដោយសារថាការវាយតម្លៃជាច្រើនកន្លងមក មិនបានកំណត់អត្តសញ្ញាណហានិភ័យឱ្យបានត្រឹមត្រូវទេ។

អង្គការអុកស្វាមយល់ឃើញថា ការប្រែប្រួលជាវិជ្ជមានណាមួយអាស្រ័យលើលទ្ធភាពរបស់សហគមន៍មូលដ្ឋានដែលជាអ្នកទទួលផល បញ្ចេញសំឡេងរបស់ខ្លួននៅក្នុងដំណើរការនៃគម្រោងនោះ។ ក្នុងនាមជាប្រជាជននៅមូលដ្ឋាន ពួកគេគួរតែជាអ្នកដែលគម្រោងទាំងនេះចាត់ជាអ្នកទទួលផល។ ជារឿយៗ សហគមន៍ទាំងនេះជាអ្នករែកពន់នូវផលប៉ះពាល់អវិជ្ជមាននៅពេលណាមានហេតុការណ៍អាក្រក់កើតឡើង។ គោលនយោបាយ ឬទម្លាប់អនុវត្តដែលរៀបចំឡើងដោយអ្នកជំនាញច្រើនតែមិនសូវមានលទ្ធផលល្អប្រសើរ ជាពិសេសនៅពេលដែលក្រុមអ្នកជំនាញភ្លេចគិតឱ្យបានល្អិតល្អន់ពីអ្វីដែលជាសេចក្ដីត្រូវការរបស់សហគមន៍។

*លោក ផេង ស៊ីវ៉ាត អនុប្រធានអង្គការមូលដ្ឋាននៅក្នុងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា មានប្រសាសន៍ថា៖ «យើងបារម្ភ និងខ្លាចលែងហ៊ានដាំបន្លែ និងដំណាំនានាឡើងវិញ ក្រោយពីដំណាំត្រូវបានទឹកជំនន់បំផ្លាញអស់មក។ អ្នកភូមិដែលមានសាច់ញាតិរស់នៅក្នុងប្រទេសឡាវ អះអាងថា ទឹកជំនន់ដែលបណ្ដាលមកពីការបាក់ទំនប់នោះនឹងមានម្ដងទៀត។»*

ក្ដីព្រួយបារម្ភរបស់ពួកគាត់គឺជាការត្រឹមត្រូវ ពីព្រោះថាតំបន់នោះអត់មានប្រព័ន្ធប្រកាសអាសន្នជាមុនដែលដំណើរការទេ។ អង្គការអុកស្វាមរកឃើញថា តំបន់ដែលមានប្រព័ន្ធប្រកាសអាសន្នជាមុននៅថ្នាក់សហគមន៍អនុញ្ញាតឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មានឆាប់រហ័ស និងមានប្រសិទ្ធភាពក្នុងការសង្គ្រោះជីវិត និងចំណាយអស់តិចតួចប៉ុណ្ណោះក្នុងការរៀបចំបង្កើតប្រព័ន្ធនេះឡើង។

ដើម្បីរៀនសូត្រពីគ្រោះមហន្តរាយនេះ យើងមិនអាចដើរតាមរបៀបវារៈអភិវឌ្ឍន៍ចាស់បានទេ តែត្រូវគិតគូរដោយប្រុងប្រយ័ត្នលើផ្នែកសុវត្ថិភាព។ គំនិតផ្ដួចផ្ដើមគម្រោងទំនប់វារីអគ្គិសនី ចាំបាច់ត្រូវពិចារណាអំពីទស្សនៈរបស់សហគមន៍ មិនថាពួកគេរស់នៅដើមខ្សែទឹកខាងលើ ឬខាងក្រោមខ្សែទឹកនោះទេ។
ការខកខានណាមួយក្នុងការពិចារណានេះ នឹងបន្សល់ទុកឱ្យយើងនូវការអភិវឌ្ឍដែលនាំផលប្រយោជន៍ឱ្យមនុស្សមួយក្ដាប់តូចតែប៉ុណ្ណោះ ជាមួយនឹងការខាតបង់ដែលប្រជាជនភាគច្រើនជាអ្នករាប់រង។ ហើយស្ថានភាពបែបនេះ គឺជាតម្លៃមួយខ្ពស់ក្រៃលែងសម្រាប់សហគមន៍មូលដ្ឋានជាអ្នកបង់ខាត៕


ស្ត្រីម្នាក់ពរកូនក្នុងភូមិដែលត្រូវបានបំផ្លិចបំផ្លាញ ដោយសារទឹកជំនន់ ក្នុង Sanamxai ខេត្ត Attapeu ប្រទេសឡាវ ទី២៦ ខែកក្កដា។ រូបថត: Nhac Nguyen/AFP

# ទស្សនវិស័យ

## ដំណើរការអភិវឌ្ឍថ្មីៗរបស់កម្ពុជា



## ឯកឧត្តម សាយ សំអាល់

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

*«ខ្ញុំគិតថា នៅក្នុងរយៈពេល១០ឆ្នាំខាងមុខទៀត យើងនឹងឈានដល់យុគសម័យមាសមួយ ដោយសារប្រជាជនទទួលបានការអប់រំខ្ពស់ជាងមុន។ ពួកគេទទួលបានចំណេះដឹងទូលំទូលាយជាងមុន ហើយពួកគេអាចបំលែងចំណេះទាំងនោះទៅជាធុរកិច្ច។ ដូច្នេះខ្ញុំមើលឃើញថា កម្ពុជានឹងអាចដើរលឿនជាងមុន។»*

**តើឯកឧត្តម មើលឃើញថាកម្ពុជានឹងអភិវឌ្ឍទៅយ៉ាងដូចម្តេចនៅពេលខាងមុខ?**

ទន្ទឹមនឹងការពេញចិត្តចំពោះសមិទ្ធផលប្រវត្តិសាស្រ្ត ដែលកម្ពុជាសម្រេចបានកន្លងមក យើងចង់ឃើញកម្ពុជាក្លាយជាប្រទេសចំណូលខ្ពស់ ដែលមានភាពរឹងមាំ មានមោទនភាពជាតិ និងជាប្រទេសគំរូនៅក្នុងតំបន់ នៅក្នុងរយៈពេល៣០ ទៅ៤០ឆ្នាំខាងមុខទៀត។ យើងមានមហិច្ឆតាខ្ពស់ទៅលើកម្ពុជានាពេលអនាគត។

ការពិតណាស់ យើងឃើញថា ទាំងប្រជាជនកម្ពុជាក៏ដូចជារាជរដ្ឋាភិបាលចង់បានការអភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីអភិវឌ្ឍកម្ពុជាបាន យើងមិនអាចមើលរំលង ឬចោលផ្នែកណាមួយឡើយនៅក្នុងសង្គម។ យើងត្រូវតែឆ្ពោះជំហានទៅមុខទាំងអស់គ្នា។ បើយើងក្រឡេកមើលទៅកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមក ដែលចាប់តាំងពីកម្ពុជាទទួលបានសន្តិភាពពេញលេញក្នុងឆ្នាំ១៩៩៨ និងបន្ទាប់ពីយើងបានអនុវត្តគោលនយោបាយឈ្នះ ឈ្នះ សេដ្ឋកិច្ចកម្ពុជាមានការកើនឡើងក្នុងរង្វង់៧% ក្នុងមួយឆ្នាំ។ យើងមើលឃើញការផ្លាស់ប្តូរជាវិជ្ជមានជាច្រើននៅក្នុងសង្គមយើង។ ប្រជាជនក្នុងកម្រិតមធ្យមមានចំនួនកើនឡើងច្រើន បើប្រៀបនឹងពីមុន។

**តើការអភិវឌ្ឍនេះមានន័យអ្វីចំពោះរដ្ឋមន្ត្រីក្រសួងបរិស្ថាន?**

នៅក្នុងក្រសួងបរិស្ថាន យើងមានការវាយតម្លៃផលប៉ះពាល់បរិស្ថានច្បាស់លាស់។ រាល់គម្រោងអភិវឌ្ឍទាំងអស់ យើងត្រូវតែធ្វើការវាយតម្លៃ ថាតើគម្រោងវិនិយោគទាំងនោះមានផលប៉ះពាល់ដល់សង្គម បរិស្ថាន វប្បធម៌ និងសេដ្ឋកិច្ចយ៉ាងណា។ ដូច្នេះរាល់ការអភិវឌ្ឍរបស់យើង ក៏យើងបានធ្វើការគិតគូរពិចារណាផងដែរ។ យើងបានធ្វើការសិក្សាថា ការអភិវឌ្ឍណាដែលត្រូវជាមួយនឹងគម្រោងអភិវឌ្ឍយុទ្ធសាស្រ្ត ក៏ដូចជាសេដ្ឋកិច្ច ដែលយើងអាចធ្វើបាន។

យើងក៏សិក្សាដែរថា គម្រោងណាដែលពាក់ព័ន្ធទៅនឹងវប្បធម៌ ប្រជាជន ដែលយើងអាចធ្វើការអភិវឌ្ឍ ក៏ដូចជាចូលរួមក្នុងការអភិវឌ្ឍពិភពលោកផងដែរ។ ជាឧទាហរណ៍ នៅក្នុងក្រសួងបរិស្ថាន យើងមានក្រុមប្រឹក្សាអភិវឌ្ឍប្រកបដោយចីរភាព។ ក្រុមប្រឹក្សានេះមានគោលដៅចំបងឆ្លើយតបដល់គោលការណ៍អភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិផងដែរ។

ចូលមើលវីដេអូ
https://www.youtube.com/watch?v=xzi8_LTBklk



# កែវ គូនីទ្យា

សហគ្រិនវ័យក្មេង និងជាអ្នកសរសេរប្លុក

**តើកញ្ញាយល់ឃើញយ៉ាងណា ចំពោះ ការអភិវឌ្ឍនៅកម្ពុជា នាពេលបច្ចុប្បន្ននេះ ?**

ខ្ញុំគិតថា ប្រទេសកម្ពុជាបាននឹងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស ជាពិសេសនៅក្នុងវិស័យជំនួញ និងសេវាកម្ម។ យើងអាចមើលឃើញថា បរទេសចាប់អារម្មណ៍មកវិនិយោគនៅកម្ពុជា ដោយសារតែកម្ពុជាមានទីផ្សារសេរី។ ប៉ុន្តែទោះចង់ ឬមិនចង់ ទីផ្សារនេះនឹងមានអ្នកចំណេញ និងខាត។ តែនៅទីណាក៏ដោយ ដែលគេអនុវត្តទីផ្សារសេរីនោះ នឹងមានឥទ្ធិពលទាំងព្រមទៅលើទាំងអ្នកផ្តល់សេវា និងអ្នកទទួលសេវា។ ជាលទ្ធផល គឺវាត្រូវការពេលវេលា ដើម្បីទទួលបានផលចំណេញ។

ដូច្នេះ យើងត្រូវតែសួរខ្លួនឯង ក្នុងនាមជាយុវជន ដែលរស់នៅកម្ពុជា ថាតើយើងអាចទទួលនូវផលប្រយោជន៍ចេញពីការអភិវឌ្ឍ ដែលកំពុងដុះដាលសព្វថ្ងៃនេះ ដោយរបៀបណា? តើភាសាអ្វី ដែលយើងត្រូវរៀនបន្ថែម ហើយថាតើជំនាញអ្វី ដែលយើងត្រូវការនោះ?

ទី២នោះគឺ កម្ពុជា គឺជាផ្នែកមួយនៃអាស៊ាន។ អាស៊ានកំពុងលូតលាស់យ៉ាងរឹងមាំ។ សូម្បីតែយុវជនក៏ត្រូវតែរៀនជំនាញថ្មី ដើម្បីប្រកួតប្រជែងជាមួយយុវជនដែលមានកម្លាំងពេញក្នុងតំបន់ ក៏ដូចជាក្នុងវិស័យជំនួញ។ នេះគឺជាអ្វីដែលពួកគេត្រូវតែដឹង។

**តើការអភិវឌ្ឍនៅកម្ពុជានាពេលខាងមុខ ត្រូវបន្តទៅដោយរបៀបណា ?**

ខ្ញុំគិតថា ប្រទេសកម្ពុជា ក្នុងរយៈពេល៥ឆ្នាំទៅមុខ គួរតែផ្តោតលើការផ្តល់សេវាកម្ម ដោយសាតែប្រទេសកម្ពុជាមានប្រជាជនតែ១៥លាននាក់ បើប្រៀបធៀបនឹងប្រទេសឥណ្ឌូនេស៊ីមានដល់ទៅ២០០លាននាក់។ អញ្ចឹង យើងនៅមានចំនួនតិចមែនទែន។ ប៉ុន្តែ ក៏មានប្រទេសដែលមានចំនួនប្រជាជនតិចជាងយើងដែរ ដូចជាប្រទេសប្រ៊ុយណេ និងប្រទេសសិង្ហបុរី។ ប៉ុន្តែហេតុអ្វីបានជាសិង្ហបុរីរឹងមាំខ្លាំងម្ល៉េះ? សិង្ហបុរីមានបទពិសោធន៍ទៅនឹងកំណើនហិរញ្ញវត្ថុ ដោយសារតែប្រទេសនេះផ្តោតលើផ្នែកធំៗ ដូចជាកំពង់ផែ។ កំពង់ផែគឺមានអាត្រាកំណើនខ្ពស់ និងផលប្រយោជន៍សេដ្ឋកិច្ចខ្ពស់។ ប្រទេសកម្ពុជាមានប្រជាជនវ័យក្មេង ពី៦០ទៅ៧០% ដែលមានអាយុក្រោម៣០ ឬ៣៥ឆ្នាំ។ នេះគឺជាសក្តានុពលដ៏ខ្លាំងក្លាមួយ។

យើងឃើញថា ពួកគាត់មានកម្លាំងពេញលេញ។ សួរថាតើពួកគាត់អាចធ្វើអ្វីបានខ្លះ? ដូចជាផ្នែកសេវាកម្ម យើងចេះភាសា យើងអាចផ្តោតសំខាន់លើសេវាកម្ម ដែលមិនត្រឹមតែផ្តល់សេវាកម្មក្នុងស្រុក ប៉ុន្តែយើងអាចធ្វើការក្នុងតំបន់អាស៊ាន ឬក៏យើងអាចទៅឆ្ងាយជាងហ្នឹងទៀត។

*«យុវជនខ្មែរត្រូវតែពិចារណាឡើងវិញ ពីអ្វីដែលខ្លួនចង់បាន នាពេលអនាគត ហើយតើពួកគេចង់ឃើញកម្ពុជាដើរទៅផ្លូវណា? ប្រសិនបើយើងពង្រឹងការអប់រំរបស់យើង សមត្ថភាពផ្នែកភាសា ជំនាញបច្ចេកទេស នោះយើងនឹងមានសមត្ថភាព ដូចអ្នកដទៃហើយ។ យើងអាចចាប់យកឱកាសទាំងនោះ ហើយយើងត្រូវរៀនឱ្យច្រើនពីពួកគេ»។*

ចូលមើលវីដេអូ
https://www.youtube.com/watch?v=zSxAQq6WYak



# ដាំ ចន្ទី

ជនជាតិទំពួន និងនាយិការ អង្គការសមាគមខ្មែរលើ

**តើអ្នកមីងមានទស្សនៈយ៉ាងណា ទៅលើការអភិវឌ្ឍ របស់ប្រទេសកម្ពុជា ក្នុងរយៈកាលថ្មីៗនេះ?**

ការអភិវឌ្ឍក្នុងតំបន់ជនជាតិដើម ហាក់ដូចជាលឿនមែនទែន ជាពិសេសការផ្តល់ដីសម្បទានដល់ក្រុមហ៊ុនធំៗ។ ខ្ញុំមិនជំទាស់នឹងការអភិវឌ្ឍនោះទេ រដ្ឋាភិបាលអភិវឌ្ឍឱ្យមានការរីកចម្រើន។ ប៉ុន្តែពួកខ្ញុំជនជាតិដើមភាគតិចពុំទាន់ទទួលបានចំណេះដឹងស៊ីជម្រៅ អំពីការអភិវឌ្ឍនៅឡើយទេ។

បញ្ហាចំបង គឺមិនបានធ្វើការបែងចែកថា តំបន់ណាគួរអភិវឌ្ឍ តំបន់ណាគួរទុកសម្រាប់ទំនុកសក្ការៈ ឱ្យជនជាតិដើមភាគតិចប្រើប្រាស់ តាមប្រពៃណី។ ជាក់ស្តែង តំបន់ព្រៃធម្មជាតិមានទំហំធំ ពោរពេញទៅដោយព្រៃអារក្ស កន្លែងប្រមូលផលអភិរក្សព្រៃឈើរបស់សហគមន៍ និងកន្លែងប្រមូលផលបន្លែធម្មជាតិ។

ជនជាតិដើមភាគតិចពុំទាន់ទទួលបានព័ត៌មានគ្រប់គ្រាន់ ក្នុងការពិគ្រោះយោបល់ និងការព្រមព្រៀងក្នុងផ្លូវច្បាប់។ ដូចពួកយើងដឹងហើយ ពួកខ្ញុំជនជាតិដើមភាគតិច ចំណេះដឹងនៅមានកម្រិត ទាក់ទងទៅនឹងការប្រើប្រាស់ភាសាខ្មែរ ច្បាប់ និងគោលការណ៍ផ្សេងៗ។ ការផ្សព្វផ្សាយនៅថ្នាក់ជាតិមានភាពទូលំទូលាយ ប៉ុន្តែថ្នាក់មូលដ្ឋាននៅមានកម្រិតខ្លាំង។

**តើអ្នកមីងគិតថា៥ឆ្នាំទៅមុខទៀត វិស័យអ្វីដែលសំខាន់ សម្រាប់ប្រទេសកម្ពុជា?**

ផ្នែកអប់រំជាបង្គោលធំ។ កាលណាមនុស្សចេះអក្សរ រៀនបានជ្រៅជ្រះ ពួកគាត់អាចការពារ វប្បធម៌ប្រពៃណី ជួយលើកស្ទួយជីវភាពរស់នៅរបស់ពួកគាត់ឱ្យបានសមរម្យ និងជួយអ្នកដទៃផងដែរ។ អង្គការសមាគមខ្មែរលើ ក៏ធ្វើការជាមួយយុវជនច្រើនក្នុងរឿងនេះផងដែរ ដោយមានការបណ្តុះបណ្តាលសិស្សជនជាតិដើមភាគតិច ពីថ្នាក់ទី៧ដល់ទី១២ ដោយផ្តល់ជាកន្លែងស្នាក់នៅដល់ពួកគេ។ តាំងពីឆ្នាំ២០០៨មក សិស្សនៅក្នុងអង្គការពួកយើង ដែលប្រឡងជាប់បាក់ឌុប មានចំនួនប្រមាណ ៣០០នាក់។ ដូច្នេះពួកយើងស្នើសុំរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជនផ្សេងៗទៀតឱ្យជួយជាអាហារូបករណ៍ ដើម្បីឱ្យក្មួយៗ បានបន្តការសិក្សាទៅថ្នាក់សាកលវិទ្យាល័យទៅភ្នំពេញ។

ហេតុដូចនេះហើយ បើអភិវឌ្ឍក្នុងតំបន់របស់ពួកគាត់ សម្បទានដីក៏ដោយ ដាំកៅស៊ូក៏ដោយ សំណូមពរឱ្យអាជ្ញាធរពាក់ព័ន្ធឱ្យមានការពិភាក្សា ឱ្យបានស៊ីជម្រៅ ហើយគួរធ្វើការសិក្សាពីវប្បធម៌ប្រពៃណីរបស់គាត់ និងធ្វើឡើងក្នុងភាសារបស់គាត់ ដើម្បីឱ្យពួកគាត់ងាយស្រួលយល់ និងមានទំនាក់ទំនងល្អ នេះជាបទពិសោធន៍របស់ខ្ញុំ ដែលបានធ្វើការជាមួយគាត់។

*«ក្នុងការអភិវឌ្ឍ សូមឱ្យមានការចូលរួមពិគ្រោះយោបល់ ធ្វើការឯកភាពគ្នាជាមុន ឱ្យមានការរក្សាទុក តំបន់ សក្ការៈបូជា តំបន់ប្រពៃណី តំបន់ព្រៃឈើ ព្រៃកប់ខ្មោច ព្រៃបំរុងទុកមួយចំនួន។ បើសិនណាមាន ភាពស្មោះត្រង់ជាមួយគ្នា និយាយឱ្យច្បាស់ជាមួយគ្នា វាអាចកាត់បន្ថយបញ្ហាទៅអនាគតជាច្រើន ខាងក្រុមហ៊ុនក៏ចំណេញ ខាងសហគមន៍ក៏ចំណេញដែរ។»*



# វ៉េត សុវណ្ណពន្លឺ

អ្នកអប់រំតាមសហគមន៍ អង្គការសុខភាពបុរសនៅកម្ពុជា

*«ខ្ញុំគិតថា អ្វីដែលជាអទិភាព សម្រាប់អភិវឌ្ឍប្រទេសកម្ពុជា នៅ៥ឆ្នាំខាងមុខទៀតគឺ ការទទួលបានការងារ កំណើននៃប្រាក់កម្រៃ ភាពធានារ៉ាប់រងផ្សេងៗ ជាពិសេសមានការបញ្ចេញយោបល់ដោយបើកចំហរ មានភាពស្មើគ្នា ក្នុងការរស់នៅរវាងអ្នកមានអំណាច និងប្រជាជនសាមញ្ញ និងមានការគាំទ្រក្នុងផ្លូវច្បាប់ នូវការរៀបការរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា»។*

**តើលោកយល់ឃើញយ៉ាងណាដែរ ចំពោះការអភិវឌ្ឍរបស់ប្រទេសកម្ពុជាក្នុង ពេលថ្មីៗនេះ?**

ចំពោះការអភិវឌ្ឍក្នុងប្រទេសកម្ពុជានាពេលថ្មីៗ ខ្ញុំយល់ឃើញថា វាមានភាពរីកចម្រើនលើវិស័យច្រើនដូចជា ហេដ្ឋារចនាសម្ព័ន្ធ សំណង់ អគារ សាលារៀន ស្ពាន ថ្នល់ ជាដើម។ តួយ៉ាង ដូចជាការបោះឆ្នោតថ្មីៗនេះ គឺបានប្រព្រឹត្តទៅយ៉ាងល្អ។ ចំពោះប្រជាជនមួយចំនួន ហាក់មានភាពរីករាយក្នុងការរស់នៅជាមួយការរីកចម្រើនផ្សារទំនើប កន្លែងកម្សាន្តនានា។

ការអភិវឌ្ឍមួយនេះមានន័យណាស់សម្រាប់ប្រជាជនទាំងមូល រួមទាំងខ្ញុំផងដែរ ព្រោះមនុស្សទាំងអស់គ្នា តែងតែចង់បានអ្វីដែលថ្មី ឃើញអ្វីដែលថ្មីប្លែក ឃើញសេដ្ឋកិច្ចជាតិរីកចម្រើន ដើរទៅមុខ និងមានភាពរស់រវើក ស៊ីវិល័យ និងទាន់សម័យក្នុងការរស់នៅ។

ការអភិវឌ្ឍនេះទៀតសោត ក៏បានផ្តល់ឱកាសការងារជាច្រើនដល់ប្រជាជនខ្មែរ ដែលនឹងអាចផ្តល់បាននូវការគាំពារដល់មនុស្សចាស់ជរា កុមារ និងស្ត្រីមេម៉ាយជាដើម។

**តើលោកចង់ឱ្យមានការរីកចម្រើនផ្នែកអ្វីសម្រាប់រយៈពេល៥ឆ្នាំទៅមុខ?**

ឥឡូវនេះ ប្រជាជនខ្មែរមានការយល់ដឹងច្រើន ដោយមួយផ្នែកធំបានលុបបំបាត់នូវការរើសអើង ការប្រើអំពើហិង្សា និងភាពអសន្តិសុខ។ ទោះបីពេលខ្លះវានៅតែកើតមាន តែវាគ្រាន់តែជាផ្នែកមួយតូចនៃមនុស្សមួយចំនួនប៉ុណ្ណោះ។ ដូច្នេះ អ្វីដែលខ្ញុំចង់បានបំផុតនោះ គឺចង់ឱ្យមនុស្សមួយចំនួនបើកចិត្តគំនិតឱ្យទូលំទូលាយមកទទួលយក និងបោះបង់ចោលការប្រើអំពើហិង្សា និងការរើសអើងលើគ្រប់ផ្នែកជាពិសេស ចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។

មនុស្សទាំងអស់គ្នាគួរគប្បីចូលរួមជួយសង្គម មនុស្សធម៌ និងឱ្យតម្លៃគ្នាទៅវិញទៅមក។ សំខាន់ជាងនេះទៅទៀត អ្វីដែលជាអទិភាពសម្រាប់អភិវឌ្ឍប្រទេសកម្ពុជា នៅ៥ឆ្នាំខាងមុខទៀត គឺការទទួលបានការងារ កំណើននៃប្រាក់កម្រៃ ភាពធានារ៉ាប់រងផ្សេងៗ ជាពិសេសមានការបញ្ចេញយោបល់ដោយបើកចំហរ មានភាពស្មើគ្នា ក្នុងការរស់នៅរវាងអ្នកមានអំណាច និងប្រជាជនសាមញ្ញ និងមានការគាំទ្រផ្លូវច្បាប់ នូវការរៀបការរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា៕

# ព្រឹត្តិការណ៍ខាងមុខ

## ខែតុលា

### កិច្ចប្រជុំ

ក្នុងតំបន់ស្តីពីកិច្ចគាំពារសង្គម
ខេត្តសៀមរាប

## ខែវិច្ឆិកា

### ពិធីសម្ពោធ

គម្រោងប្លុកឆេន
ដើម្បីជីវភាពកសិករស្រូវសរីរាង្គ
ពីប្រទេសកម្ពុជា (ប្លូករាយស៍)

## ខែធ្នូ

### ពិធីសម្ពោធ

ពិធីសម្ពោធ GRAISEA 2 នៅកម្ពុជា
ការពង្រឹងសិទ្ធិអំណាចរបស់កសិករ
ខ្នាតតូចស្ត្រី និងបុរស តាមរយៈ
កម្មវិធីធុរកិច្ចមានការទទួលខុសត្រូវ
និងច្រវាក់តម្លៃតាមបែបបរិយាប័ន្ន

សូមចូលមើលព្រឹត្តិការណ៍ទាំងអស់
*https://cambodia.oxfam.org/calendar-node-field-date/month*

# ព័ត៌មាន

**ឯកអគ្គរដ្ឋទូតប្រទេសបែលហ្ស៊ិក អញ្ជើញសួរសុខទុក្ខកម្មករកម្មការនី ដែលរងការរើសអើង**

នៅដើមខែកក្កដា ឆ្នាំ២០១៨ លោក **Philippe Kridelka** ឯកអគ្គរដ្ឋទូតប្រទេសបែលហ្ស៊ិក បានអញ្ជើញធ្វើទស្សនកិច្ចការងារអង្គការដៃគូរបស់អុកស្វាម ដែលធ្វើការក្នុងកម្មវិធីកិច្ចគាំពារសង្គមប្រកបដោយបរិយាប័ន្ន និងសមធម៌ សម្រាប់កម្មករកម្មការនី នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅតំបន់អាស៊ាន ជាកម្មវិធីមានរយៈពេលប្រាំឆ្នាំ (២០១៧-២០២១) ក្រោមជំនួយហិរញ្ញវត្ថុពីទីភ្នាក់ងារអភិវឌ្ឍន៍បែលហ្ស៊ិក។

ដៃគូចំនួនបីដែលបានជួបក្នុងពេលនោះរួមមានអង្គការបណ្ដាញការងារស្ត្រីរួបរួមគ្នា (WNU) សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) និងសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU) ពួកគេបានចែករំលែកអំពីកម្មវិធីរបស់គេ បញ្ហាប្រឈមនានាដែលកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធជួបប្រទះ។



អុកស្វាមលើកទឹកចិត្តយុវជនឱ្យដាក់ពាក្យចូលរួមកម្មវិធីសហគ្រិននៅ Impact Hub

កិច្ចពិគ្រោះយោបល់ថ្នាក់ក្រោមជាតិស្ដីពី «ការផ្ដល់ធាតុចូលរបស់អង្គការសង្គមស៊ីវិលដើម្បីរួមចំណែកដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣» នៅខេត្តសៀមរាប

ស្ត្រីក្នុងភាពជាអ្នកដឹកនាំប្រឆាំងនឹងភាពមិនអនុគ្រោះ - វិទ្យុផ្កាឈូក

អុកស្វាមចូលរួមជាមួយវេទិកាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ធ្វើការសម្របសម្រួលកិច្ចសន្ទនាជាមួយរាជរដ្ឋាភិបាលកម្ពុជាស្ដីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

កម្មវិធីសន្ទនាស្ដីពី «ការទទួលខុសត្រូវផ្នែកសង្គមរបស់ធុរកិច្ច» - ទូរទស្សន៍បាយ័ន

វេទិកាតំបន់ស្ដីពីបន្លែ ឆ្នាំ២០១៨ - ការចែករំលែកចំណេះដឹងដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យបន្លែ


© អុកហ្វាមនៅប្រទេសប៉ាគីស្ថាន

# អុកស្វាមនៅជុំវិញពិភពលោក

## នៅប្រទេសប៉ាគីស្ថាន

អុកស្វាមកំពុងធ្វើការពង្រឹងអំណាចដល់ស្ត្រី វ័យក្មេងឱ្យក្លាយខ្លួនជាយុទ្ធជនប្រយុទ្ធនឹង ការប្រែប្រួលអាកាសធាតុ។



## នៅប្រទេសអេក្វាឌ័រ

អុកស្វាមជំរុញលើកទឹកចិត្តឱ្យមានការ ចូលរួមរបស់ជនជាតិដើមភាគតិច រួមមានជនជាតិដើមភាគតិចមានដើម កំណើតមកពីអាហ្វ្រិក និងក្រុមជនជាតិ Montubio ក្នុងរចនាសម្ព័ន្ធអំណាច ដោយ ប្រើប្រាស់គោលនយោបាយដែលទទួល ស្គាល់ចម្រុះភាពផ្នែកវប្បធម៌។

## នៅប្រទេស ប៉ាពូអាស៊ី នូវែលហ្គីណេ

អុកស្វាមកំពុងជួយធ្វើឱ្យប្រសើរដល់ សុខភាពរបស់សហគមន៍ជនបទ តាមការ ផ្តល់លទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹក ស្អាត រចនាសម្ព័ន្ធសម្រួលសេវាអនាម័យ និងកែលម្អទម្លាប់អនុវត្តអនាម័យឱ្យប្រសើរ ជាងមុន។ ចូរយើងមើលថាតើ គ្រាន់តែ ការផ្គត់ផ្គង់ទឹកស្អាតធ្វើឱ្យសហគមន៍ទទួល ការផ្លាស់ប្តូរដូចម្តេចខ្លះ។

# អំពីអុកស្វាម

អង្គការអុកស្វាម បានធ្វើការគាំទ្រការអភិវឌ្ឍប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ ជាអង្គការដំបូងបង្អស់ ដែលប្រតិបត្តិការក្នុងប្រទេសកម្ពុជាក្រោយការដួលរលំ នៃរបបខ្មែរក្រហម។ អុកស្វាម ធ្វើការយ៉ាងសកម្មលើកម្មវិធីអភិវឌ្ឍជាច្រើន ក្នុងការលើកកម្ពស់អំណាចសេដ្ឋកិច្ចស្ត្រី ការចិញ្ចឹមជីវិតសម្រាប់ក្រុមងាយរងគ្រោះ កម្មវិធីគ្រប់គ្រងធនធានធម្មជាតិ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងថាមពលប្រកបដោយចីរភាព បរិយាប័ន្នហិរញ្ញវត្ថុ កិច្ចគាំពារសង្គម និងការងារសមរម្យ កសិកម្មបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងប្រកបដោយចីរភាព ការត្រៀមបង្ការគ្រោះមហន្តរាយ និងជំនួយមនុស្សធម៌ ការធ្វើការជាមួយពលរដ្ឋ និងហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ។



# សូមអរគុណដៃគូទាំងអស់គ្នា !

អង្គការអុកស្វាម មានសេចក្ដីសោមនស្សចំពោះការគាំទ្រ កិច្ចសហការ និងទំនាក់ទំនងយូរអង្វែងជាមួយដៃគូទាំងអស់។ សូមអរគុណ ដែលបានចូលរួមសកម្មភាព ជាមួយអង្គការអុកស្វាម និងបានដើរតួរជាភ្នាក់ងារជម្រុញការផ្លាស់ប្ដូរដ៏សំខាន់ ដើម្បីកាត់បន្ថយភាពក្រីក្រ និងពង្រឹងអំណាចសហគមន៍។ យើងបានធ្វើដំណើរជាមួយគ្នា ដើម្បីបង្កើតសន្តិភាព និងធានាយុត្តិធម៌សង្គម។ អុកស្វាម មានមោទនៈភាពជាខ្លាំងសម្រាប់ប្រតិបត្តិការ និងកិច្ចសហការជាបន្តបន្ទាប់ជាច្រើនឆ្នាំកន្លងមក ហើយសង្ឃឹមថា យើងនឹងបន្តដំណើររួមគ្នាជាច្រើនឆ្នាំទៅមុខទៀត។

ផ្ទះលេខ ៩៤ ផ្លូវសហព័ន្ធរុស្សី
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (+៨៥៥) ២៣ ៨៨៥ ៤១២
ទូរសារ: (+៨៥៥) ២៣ ៨៨៥ ៤៥២

F: @OxfaminCambodia
T: @OxfamKH
PineehPinooh.cambodia@oxfam.org